# ឧបសោសង្ហា

# ប្រពៃណី និង នវភាព

LA TRADITION ET LA MODERNITE




ផ្ទះ បុរាណ និង សម័យ អ្នកក្រខ្មែរ

## មាតិការឿង

**អារម្ភកថា** .......... 2
**បុរាណ** .......... 5
**ប្រពៃណី និង ទម្លាប់** .......... 6
**សម័យ** .......... 7
**សម័យ និង សីលធម៌** .......... 9

# ប្រពៃណី និង នវភាព នៅស្រុកខ្មែរ

## អារម្ភកថា

នៅស្រុកខ្មែរ ក៏ដូច នៅប្រទេសនានា ក្នុង ពិភពលោក គឺ ទទួល ផលវិបាក ពី នវភាព ដែល បណ្តាល អោយមាន គម្លាត កាន់តែធំទៅៗ រវាង អ្នកមាន, មាន ចំនួនតិចបំផុត, នឹង អ្នកក្រ, មាន ចំនួន កាត់តែកើន ឡើងច្រើន, តែ នវភាព ឬ ភាពទំនើប ក៏ជា អ្នកបង្កើត, ជាពិសេស នៅក្នុង ផ្នែក សម្ភារៈ, អោយមាន សុខុមាលភាព ដល់ មនុស្សលោក សំរាប់ សំរួល ដល់ រូបកាយ នៅក្នុង ជីវិតរស់នៅ នោះដែរ ដូចយ៉ាង វិស័យ ហេដ្ឋារចនាសម្ព័ន្ធ, សុខាភិបាល, ការ ដឹកនាំ, គមនាគមន៍ៗលៗ ដែលនាំអោយ ចំណេញ ពេលវេលាច្រើន និង មាន អាយុវែង សំរាប់ ធ្វើអ្វីបានច្រើនទៀត ក្នុងជីវិត កំរិត ដោយ ពេលវេលាៗ ប៉ុន្តែ នវភាព មិនពិត ជា នាំមកអោយ មនុស្ស នូវ សុភមង្គល ទាំងអស់ បាននោះឡើយ ព្រោះ សុភមង្គល ជា ផ្លូវចិត្ត ដែល នរជនម្នាក់ៗ មាន វេទយិតភាព[1] រៀងៗខ្លួន នៅក្នុងចិត្ត, សុភមង្គលរបស់ ជនម្នាក់ វា មិនដូចគ្នានឹង ជនម្នាក់ទៀត ព្រោះ មាន ចិត្តខុសគ្នាៗ ដូច្នេះ គេអាចទុក សុខុមាលភាព ជា ទិដ្ឋភាពក្រៅ រីឯ សុភមង្គល វិញ ជាទិដ្ឋភាពក្នុង នៃ មនុស្ស ព្រោះ មនុស្ស រស់នៅក្នុង អារ្យធម៌ តែ មាន វប្បធម៌ ខុសគ្នា គឺថា ត្រូវការ សម្ភារៈ ដូចគ្នា តាម មធ្យោបាយ ដែល មាន

[1] វេទយិតភាព ; sensibilité

រៀងៗខ្លួន តែ មានកំរិត សុខមង្គលខុសគ្នា ដូចយ៉ាង អ្នកមានលុយ សប្បាយ មាន ឡានល្អជិះ រីឯ អ្នកក្រ បើមានកង់ជិះ ក៏សប្បាយណាស់ដែរៗ

តែ សេចក្តីត្រូវការ នៃ មនុស្សលោក វា មាន ការវិវត្តន៍ ព្រោះ អារ្យធម៌ក្តី និង វប្បធម៌ក្តី វា មាន ចលនា តាម ចរន្ត នៃ ការចំរើន នៃ មនុស្សជាតិ ដូចយ៉ាង អគ្គិសនី, ទឹកអនាម័យ (eau potable), ឱសថសំរាប់ព្យាបាលជម្ងឺ,សិក្សាធិការជាតិ, ការងារ, យុត្តិធម៌ៗលៗ ដែល សុទ្ធ ជា សេចក្តីត្រូវការ ចាំបាច់ នៃ មនុស្ស ដែល ទុក ជា អប្បបរមា ដើម្បី ជីវិត (minimum vital) សំរាប់ ការរស់នៅៗ អប្បបរមា ដើម្បី ជីវិតនេះ ជា មូលដ្ឋានដំបូង នៃ សុខមង្គល នៃ មនុស្សជាតិ តាំងពី សតវត្ស ទី២០មកៗ ចំណុចនេះ ឯងដែល ជា ការខុសគ្នា រវាង បូរាណ នឹង សម័យ, ដូច្នេះ និយមន័យ នៃ ពាក្យ សម័យ គឺ គ្រប់ ការរីកចំរើន ដើម្បី បំរើ មនុស្សលោក, រីឯ បូរាណ វិញ គឺជា លទ្ធវត្ថុ (chose acquise) សំរាប់ បន្តនៃ ការរីកចំរើន ដើម្បី បំរើ មនុស្សលោកៗ ដូច្នេះ មនុស្សលោកនេះឯង ជា ខ្លឹម នៃ មនុស្សជាតិ ព្រោះ មនុស្សលោក ជា នាដការ សកម្ម នៃ ការរីកចំរើន តាំងពី ដើមកំណើតដំបូង នៃ មនុស្សជាតិ សំរាប់ខ្លួនឯងៗ ការរីកចំរើន របស់ មនុស្សជាតិ គឺ សីលធម៌ កើតមក ពី សិក្ខា (apprentissage) របស់ នរជន (humain) ទៅតាម លក្ខណ: នៃ សម្បត្តិសម្ភារ: និង សីលសមាធិបញ្ញា (richesse spirituelle) របស់មនុស្សម្នាក់ៗ ដូចយ៉ាង អ្នកមានអំណាច ត្រូវស្គាល់ យុត្តិធម៌, អ្នកមានទ្រព្យ ត្រូវស្គាល់សេចក្តីសប្បុរសទាន, អ្នកក្រខ្សត់ ត្រូវ

ស្គាល់ សេរីភាព។ សិក្ខា ទាំងឡាយនេះគឺ ត្រូវធ្វើ នៅក្នុង ស្មារតី នៃ សេចក្ដី ស្នេហា ដែលជា ធាតុ នៃ មនុស្សលោក។ សិក្ខា នៃ សីលធម៌ នេះទៀត គឺ ជា ការបន្ត ពី បូរាណ ទៅសម័យ តាម ការវិវត្តន៍ នៃ បញ្ញា របស់ នរជាតិ៖ មនុស្សលោក ជា សត្វលោក ដែល មាន បញ្ញា សំរាប់ ពិចារណា ជា អចិន្ត្រៃយ៍ អោយ ស្គាល់ ការខុសត្រូវ នៅក្នុង ការរស់នៅរបស់ខ្លួន នៅក្នុង នរសង្គម។ បញ្ញា នេះឯង ដែល ជា តម្លៃសជ្ឈន្តិក: នៃ ការរស់នៅ របស់មនុស្ស ខុសពី សត្វ ទាំងពួង រស់នៅ ក្នុង សទាវគតិ នៃ សមតា នៃ ប្រព័ន្ធបរិស្ថាន ដែល ផ្ទេរ បន្ត ពូជ តាមសិក្ខា ជា ម្រឹគ បក្សី និង ត្រី គ្រប់យ៉ាង មាន នៅ ក្នុង លោកនេះ។ តាម បញ្ញា, មនុស្សលោក ជា នាដការ នៃ ការរីកចំរើន នៃ មនុស្សជាតិ រស់ ក្នុង ពេលវេលា ដោយសន្ទត, រីឯសត្វ វិញ ជា អនិរក្ស នៃ ពូជ របស់ខ្លួន រស់ ក្នុង ពេលវេលា នៃ ធម្មជាតិ រាប់ជា រដូវ។ មនុស្សលោក មាន អតីតកាល បច្ចុប្បន្នកាល និង អនាគតកាល របស់ខ្លួន ចារទុក ក្នុងសតិ ឬ ឯកសារ ក្នុង បំណង ស្វែងរក គុណាករ ឬ វិក្រិតតាព, រីឯសត្វវិញ មានតែ ការតម្រូវខ្លួន (adaptation) តាម ធម្មជាតិ ដើម្បី បន្តពូជ របស់ខ្លួន។ ដូច្នេះ មនុស្សលោក ជា តួអង្គ មាន សម្បទា ពី កំណើត នៃ វិក្រិតតាព (être doué de la perfection) ចំណែង ឯ សត្វ វិញ ជា តួអង្គ មាន សម្បទាពីកំណើត នៃ ការ តម្រូវខ្លួន ; មួយ មាន បញ្ញា អាចរក សុក្រិតតាព, មួយទៀត មាន សទាវគតិ អាចរក សុវឌ្ឍិកម្ម (amélioration)។ សុក្រិតតាព នេះឯងហើយ ជា ដំណើរ នៃ មនុស្សជាតិ ពី បូរាណ ទៅរក សម័យ ដែល គេ អោយឈ្មោះថា អារ្យធម៌។

# បូរាណ

អារ្យធម៌ ជា ជីពចលនា (mouvement vivant) មាន ដើមកំណើត រួច មាន ការវិវត្តន៍ ទៅរក សុក្រិតភាព ; សេចក្តីខ្វះ នូវ ការកែជាថ្មី នៃ បញ្ញា មិន ចេះដាច់ ដែលជា ការធ្វើឲ មាន កម្លាំងឡើងវិញ ជាអនន្ត ទាំងផ្នែក សម្ភារ: និង គំនិត គឺជា ផ្តើមសញ្ញា នូវ ការរំគាយ នៃ កម្លាំង អារ្យធម៌ បន្តិចម្តងៗរហូតរលត់ ប្បាត់សូន្យ ដូចយ៉ាង អារ្យធម៌ នៃ មហានគរខ្មែរ នោះឯងៗ ចំណេះចេះដឹងពី បូរាណ ជា កន្លោង (colonne principale) មួយ នៃ អារ្យធម៌ផង ជា សតិផង នូវ (ហើយនិង) ជា បញ្ញាផង ដែល គេទុកជា វប្បធម៌ របស់ នរសង្គម និងប្រជា ជាតិ មួយៗ ចំណេះចេះដឹង នៃ នរសង្គមមួយ តែងតែទទួល ឥទ្ធិពល ឬ ជះ ឥទ្ធិពលខ្លួន ទៅលើ នរសង្គម ដទៃទៀត ព្រោះ មនុស្សលោក ត្រូវការ ការទំនាក់ ទំនង ក្នុងការរស់នៅ របស់ខ្លួនៗ ការប្តូរ នៃ ចំណេះចេះដឹង រវាង មនុស្សម្នាក់ ទៅ មនុស្ស ម្នាក់ទៀត ឬ សង្គមមួយ ទៅ សង្គម មួយទៀត ជា ការប្តូរ ជា អនុក្កូល[2] ដល់ ការរីកចំរើន នៃ មនុស្សជាតិ តាម ការរីកចំរើន រហ័ស នូវ បច្ចេកទេស ពឹតមានវិទ្យា[3]ៗ ដូច្នេះ មនុស្សជាតិ ជា សតិ និង ឃ្លាំង គ្មានកំរិត

[2] ការប្តូរ ជាអនុក្កូល= Echange favorable ou bénéfiqueៗ

[3] ពឹតមានវិទ្យា= Science d′informationៗ

នៃ ទំហំ នៃ ចំណេះចេះដឹង នៃ មនុស្សលោក ដែលគេអាច ទៅរក យកវា មក សិក្សា ឬ ប្រើ ក្នុងគោលបំណងអ្វីមួយ ដែល គេត្រូវការ។

## ប្រពៃណី និង ទម្លាប់

ចំណេះចេះដឹង ក្នុង បូរាណកាល ជួនក្លាយ ជា ប្រពៃណី ជួនកើត ជាទម្លាប់ សំរាប់ ជីវិតាពរាល់ថ្ងៃ។ បើជា ប្រពៃណី គឺ វា មាន ក្រមសីលធម៌ (règle éthique) សំរាប់ គ្រប់គ្រង ដែល ខ្មែរយើង ហៅថា ច្បាប់បូរាណ។ បើ នរណាម្នាក់ បំពាន ច្បាប់នេះ ត្រូវគេមាក់ងាយ ឬ ទទួលទោស ដែល មានចែង នៅក្នុង ក្រមសីលធម៌។ នៅក្នុង លក្ខណ:នេះ ប្រពៃណី វា ជា ច្បាប់វិជ្ជមាន (loi positive) ផង ជា វិន័យ តុណ្ហិ សំរាប់ ការរស់នៅ ផង។

តែ ចំណេះចេះដឹង ក្នុង បូរាណកាល ជួនកើតជា ទម្លាប់ ដែល បុគ្គលម្នាក់ៗ តែងតែយកមក ប្រព្រឹត្តិ ដោយ ឥតបានគិតពិចារណា ព្រោះទម្លាប់ វាគ្មាន ក្បួន ពិតប្រាកដនោះឡើយ ដែល ជួនកាល ធ្វើទៅ មាន ផល មិនល្អ ជួន មាន ផល ល្អ, ដូច្នេះ ចរិកលក្ខណ: របស់វា គឺ អនិយតភាព (ភាពមិនប្រក្រតី) នេះឯង។ ចាស់បូរាណខ្មែរ គាត់ មាន ស្មារតី ដឹងពី ទំនាស់ នៃ ទម្លាប់ មាន នៅក្នុង សង្គម ខ្មែរ បាន ជា គាត់ ចារ ជា ពាក្យបណ្ដាំ ដោយ ប្រៀបធៀប ទៅនឹងគុណសម្បត្តិ របស់ សមន្ដជន (voisin proche) នៃ ជនខ្មែរ ថា៖ សៀមគេមានក្បួន, យួន គេមានពុត ឯចំណែកខ្មែរ វិញ មិនដែលចោលចែចូវ។ គតិរឿងនេះ ធ្វើឡើងក្នុង

គំនិត កសាង ចរិតខ្មែរ ដែល មាន ទម្លាប់ យក គំនិតសាំញ៉ាំ ធ្វើជា របបជីវិត។ ទម្លាប់ នេះឯង ជា ទំនើងចិត្ត (គំនិតសាំរ៉ាំ) យកវាមកប្រព្រឹត្ត គ្មាន ប្រព័ន្ធ និង ខ្វះ ការពិចារណា វា នឹងអាច ជា អំពើហិង្សា គ្មាន កំណត់ ដែលនាំ ទុក្ខដល់ខ្លួន ច្រើនជាង សុខ, ដូចជា ខ្មែរយើង មាន ទម្លាប់គោរព និង ខ្លាច ស្តេច ឬ អ្នកធំ ដោយ មិនបានគិត ថា ព្រោះ ហេតុអ្វី។ តែ បើ ខ្មែរយើង យក ទម្លាប់នេះមក ពិចារណា គឺ វា គ្មានអ្វី ជាខ្លឹមសារ សោះ ព្រោះ ការគោរព និង ខ្លាចគ្មាន សេចក្តីស្នេហា គឺ ស្ថិតនៅ ក្នុង សភាព អ្នកខ្សោយ គោរព អ្នកខ្លាំង នៅក្នុង ប្រព័ន្ធ អំណាច គ្មាន ច្បាប់រដ្ឋ សំរាប់ ការពារយុត្តិធម៌ ឬ គ្មាន សីលធម៌ ដែលជា ទ្វេមូលដ្ឋាន នៃ សេចក្តីស្រឡាញ់ ដូច កូន គោរព ស្រឡាញ់មាតាបិតា។ ទម្លាប់ទី ១ គឺ ខ្លាចអំណាច, រីឯ ទម្លាប់ទី២ វិញ គឺ មាន មូលហេតុ ពី សេចក្តីស្រឡាញ់ ដ៏ បរិសុទ្ធ រវាង មាតាបិតា និង កូន ព្រោះ វា មាន បដិការ (réciprocité) ដែល ជា ធម្មជាតិ នៃ មនុស្សលោក។

## សម័យ

អ្នករិះគន់ នៃ ទិដ្ឋភាពអវិជ្ជមាន នៃ បូរាណ ច្រើនមាន ព្យាកុលភាព រវាង ប្រពៃណី នឹង ទម្លាប់។ នៅស្រុកខ្មែរ នៅក្នុងជំនាន់ អាណានិគមបារាំង អ្នកចេះដឹងខ្មែរ ដែល បាន ទទួល ការអប់រំ ពី ការសិក្សាសម័យ ឬ ការសិក្សាមស្ទឹមប្រទេស តែងតែ ច្រានចោល នូវ ចំណេះចេះដឹងខ្មែរ ពី បូរាណកាល ដោយ

ទុក ជា ចំណោះ ដែល គេលែងប្រើ ៖ អ្វីដែល គេលែងប្រើ គឺ ហួសសម័យ, អ្វីដែល ហួសសម័យ គឺ ជា លជ្ជាភាព (honte) សំរាប់ខ្លួន, បើ អាន កាសែត ជាភាសាជាតិ គឺជា ការល្ងង់ខ្លៅ ស្មើនឹង អវិជ្ជា ; ទស្សនៈ ទាំងឡាយនេះ ជាស្មារតីរបស់ អ្នកចេះដឹងខ្មែរ ភាគច្រើន នៅក្នុងប្រព័ន្ធ នៃការអប់រំសម័យ នៅក្នុងសម័យអាណានិគមៗ ការបដិសេធ ទាំងអស់ នេះឯង ចោទ ជា ចំណោត ដល់ ការអប់រំជាតិ ព្រោះ ចំណោះចេះដឹង វា មាន លក្ខណៈ ជា សាកល ផង ដែល ជនខ្មែរ ត្រូវតែចេះ អោយទាន់សម័យ និងជាប្រយោជន៏ ដល់ ប្រជាជាតិ ផង ដែលជនខ្មែរ ត្រូវ មាន ករណីយកិច្ច និង កាតព្វកិច្ច កសាងខ្លួន អោយក្លាយ ជាពលរដ្ឋ មាន ការចេះដឹងៗ ដូច្នេះ ការអប់រំជាតិ មិនគ្រាន់តែមាន តួនាទី ជា អ្នកផ្តល់ ពិពិធវិជ្ជា[4] គឺ ត្រូវ ជា វិនាយក (guide moral) និង ជា អ្នកអប់រំមូលដ្ឋាន នៃ ស្មារតី នៃ ពលរដ្ឋ ដល់ យុវជន ដែល ជា ពន្លក នៃ បញ្ញាជាតិ អោយក្លាយជា ពលរដ្ឋ ជុតិមា (brillant) ចេះវិជ្ជា ហើយ ស្គាល់នូវ សីលធម៌ ដែលខ្មែរបូរាណយើង ហៅថា ជា អ្នកចេះដឹង ហើយ សម័យថ្មី មាន ឈ្មោះ ជា បញ្ញាវន្តៗ គុណសម្បត្តិ ជាបញ្ញាវន្តនេះឯង ជាការចេះដឹងសម័យ ដែល ជា រជ្ជសញ្ញាតន្ទាប់ បូរាណ ជា មួយនឹង សម័យ ដែលជា ចលករ នៃ ការរីកចំរើន ; ដូច្នេះសម័យ ជា ពន្លឺ សំរាប់ ខ្លួនឯងផង និង សំរាប់ បំភ្លឺ អ្វី ដែល ទុក ជា ការចេះដឹងនិង ទម្លាប់ មានពី បូរាណមកៗ

---

[4] ពិពិធវិជ្ជា= Instructions diversesៗ

# សម័យ និង សីលធម៌

សម័យ ជា ពន្លឺ ដូច្នេះ វា ត្រូវតាមទំនងនឹង សីលធម៌ ទើបទុកជា ពន្លឺបញ្ញា ដែល ជា ការចេះដឹង មិនបំផ្លាញ នូវអ្វី ដែល មានពី បូរាណ តែ កែច្នៃវា អោយ សមទៅតាម ការរស់នៅសម័យ ប្រកបទៅដោយ សីលធម៌ ដែលមានច្បាប់ ជា មូលដ្ឋានៗ ទង្វើ សម័យណា ដែល បំផ្លាញ ប្រពៃណី គឺជា ការបន្ត ទម្លាប់ចាស់ នៅក្នុងសម័យថ្មី តែប៉ុណ្ណោះៗ សម័យថ្មី និង គំនិតថ្មី មានភាពខុសគ្នា, មួយជា កត្តា នៃ ពេលវេលា ជាធម្មជាតិ ដែល មានដំណើរ ទៅមុខជានិច្ច, មួយទៀតជា កត្តា នៃ បញ្ញាមនុស្ស ដែលត្រូវស្វែងរក ការចេះដឹងថ្មី សំរាប់លើកថាន:ជីវភាព ទាំងផ្លូវ សម្ភារ: និង សីលសមាធិបញ្ញា (richesse spirituelle), ហើយកត្តា ទាំងពីរនេះ ត្រូវដើរ អោយ ស្របគ្នា ទើប សង្គមជាតិ ឬ នរសង្គម មាន ការរីកចំរើន ពុំនោះសោត ការរស់នៅ ក្នុងសម័យថ្មី គឺគ្រាន់តែ រស់នៅក្នុង ពេលបច្ចុប្បន្ន គ្មាន ការផ្លាស់ប្តូរ ទម្លាប់ចាស់ តែប៉ុណ្ណោះ ; ដូច ទស្សនៈវិទូ មស៊ឹមប្រទេសម្នាក់ ទូន្មាន ដល់ មនុស្សលោកថា៖ ការរីកចំរើន នៃ វិទ្យាសាស្រ្ត គ្មាន សីលធម៌ គឺ គ្រាន់តែជា បរាភព (ruine) ដល់ នរសង្គម តែប៉ុណ្ណោះៗ យើងអាចយក ការទូន្មាននេះ មក ទូរនឹង ការអភិវឌ្ឍន៍ គ្មាន សីលធម៌ គឺគ្រាន់ តែ សំរាប់ បំផ្លាញ ជីវភាពរស់នៅ នៃ អ្នកក្រ នោះឯង, ឧទាហរណ៍ ដូច រដ្ឋ រឹបអូស ដីធ្លី អ្នកក្រ យក ទៅលក់ អោយ ឈ្មួញវិនិយោគ រកតែចំណេញៗ

សម័យ គឺជា សីលធម៌ ព្រោះ ការរីកចំរើន នៃមនុស្សជាតិ គឺជាដំណើរប្រកប ដោយ ជោគជ័យ នៃ សីលធម៌ លើ អនារ្យធម៌ (អមនុស្សធម៌)ៗ តតវែតសីលធម៌ (morale victorieuse) នេះ ជា សីលធម៌ នៃ មនុស្សលោក ខុសគ្នានឹង ធម៌ សាសនា តែក៏មិនជា ដំណើរ ទៅរក ការរកឈ្នះចាញ់នឹង ទិដ្ឋិសាសនា នោះ ដែរ ព្រោះខ្លួន រស់នៅក្នុង ចរន្ត នៃ ដំណើរសម័យ តែ មិនប្បោះបង់ចោលទាំង អស់ នូវ ធម៌សាសនា ដែល ជា យោងដើម នៃ ស្មារតី យល់ដឹង អំពីអ្វី ជា អំពើ ល្អ និង អំពើ អាក្រក់ៗ ស្មារតី នេះ ជា ទម្រង់ នៃ មនុស្សនិយម ក្នុង ជំនឿ សាសនា, រីឯសីលធម៌ នៃ មនុស្សលោក វិញ គឺមានធាតុ ជា មនុស្សនិយមដែរ តែ ជា មនុស្សនិយម មជ្ឈន្តវិវិនី (humanisme modérateur), គឺ អ្នកទប់ អោយនៅជាកណ្តាល រវាង ជំនឿសាសនា និង ការវិវត្តន៍ នៃ មនុស្សជាតិ សំដៅ ទៅ រក ការរីកចំរើន នៃ បញ្ញាមនុស្ស ពី សម័យ មួយ ទៅ សម័យថ្មី មួយទៀត គ្មានទីបំផុតៗ អធុនិក (le contemporain) ជា មនុស្សសម័យ ទូរនឹង មនុស្ស បូរាណ តែ ជា តួអង្គ នៃ សេចក្តីចម្រើន (être évolutif) នៅក្នុង សម័យ ដែល ខ្លួន កំពុងរស់នៅ ដើម្បី ការរីកចំរើន នៃ មនុស្សជាតិ ក្នុង ចរន្ត នៃ ដំណើរ នៃ សីលធម៌ នៃ មនុស្សលោក, ដូច្នេះ សម័យ គឺ ជា សីលធម៌ថ្មី តម្រូវនឹង របប ជីវិតថ្មី សំរាប់ ការរស់នៅរបស់ មនុស្សលោក អធុនិក នោះឯងៗ

យើង សួរសំណួរ ថា តើ សម័យ នៃ សង្គមខ្មែរ មាន លក្ខណៈ ខុសគ្នានឹង បូរាណ នៃ សង្គមខ្មែរ ដែរឬទេ ?